# មហាបណ្ឌិត

ខ្ញុំជាបណ្ឌិត    អ្វីដែលខ្ញុំគិត
គឺពិតជាត្រូវ    ប្អូនៗនៅខ្សោយ
កុំសាកកុំសួរ    ខ្ញុំគិតគ្រប់ផ្លូវ
ត្រូវគ្រប់ជ្រោយជ្រុង។

ខ្ញុំជាបណ្ឌិត    អ្វីដែលខ្ញុំគិត
ត្រូវមិនដែលលង់    លើកមុនខូចខាត
ព្រោះជនអន់ពង្ស    ខ្លួនឯងពិតល្ងង់
ធ្វើចេះជាងខ្ញុំ។

ខ្ញុំជាបណ្ឌិត    អ្វីដែលខ្ញុំគិត
មុខត្រូវទាំងដុំ    ដូច្នេះត្រូវតាម
កុំនៅញ៉ៀមញ៉ុម    ត្រូវតែតាមខ្ញុំ
ព្រោះខ្ញុំប្រាជ្ញវៃ។

ខ្ញុំជាបណ្ឌិត អ្វីដែលខ្ញុំគិត
ខុសអ្នកដទៃ គិតឡូយគ្រប់រឿង
គ្រប់គ្រឿងលកលៃ ព្រោះខ្ញុំនេះនៃ
រៀនបានខ្ពស់ណាស់។

ខ្ញុំជាបណ្ឌិត អ្វីដែលខ្ញុំគិត
ចំរឿងហើយច្បាស់ ព្រោះខ្ញុំរៀនច្រើន
ខ្ញុំមនុស្សចាស់ អ្វីៗក៏ច្បាស់
ខ្ញុំមិនអួតទេ។

ខ្ញុំជាបណ្ឌិត បងប្អូនជុំជិត
កុំគិតវៀចវេ ព្រោះគ្មានអ្នកចេះ
ស្មើរូបខ្ញុំទេ ខ្ញុំរៀនស្រុកគេ
ទើបដឹងប៉ុណ្ណេះ។

ខ្ញុំជាបណ្ឌិត អ្វីដែលខ្ញុំគិត
ពិតជាមិនខុស គិតចំហើយជ្រៅ

ត្រូវគ្មានចន្លោះ ដូច្នេះពិតខុស

បើអ្នកតបត។

ខ្ញុំជាបណ្ឌិត បងប្អូនញាតិមិត្ត

ខ្ញុំសូមអង្វរ គោរពខ្ញុំមក

កុំសួរចារច កុំរកខ្មៅស

ឱ្យខ្ញុំភ័យរៀង។

ខ្ញុំឃំឥឡូវ បើមីងម៉ែឪ

មិនស្តាប់សូរសៀង មិនគោរពខ្ញុំ

ហើយគិតគេចរៀង នោះពិតទាត់ទាង

បណ្ឌិតខ្ញុំឃំ។

ភ្នំពេញ ០៦.០៥.០៨

សួយ ឡូត